# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា
CAMBODIA WATCHDOG COUNCIL INTERNATIONAL


គ្រីស្ទានសាន់ (ន័រវេស៍) ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២០

# សេចក្តីថ្លែងការណ៍

## ជំទាស់គម្រោងសាងសង់បន្ថែមនូវស្តូបវៀតណាម ឬស្តូបនយោបាយឈ្នះៗ នៅកម្ពុជា

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សូមប្រឆាំងជំទាស់ដាច់អហង្កា ចំពោះគម្រោងណាមួយរបស់ក្រសួងការពារជាតិ និង រដ្ឋាភិបាលលោក ហ៊ុន សែន ក្នុងការសាងសង់បន្ថែមនូវស្តូបវៀតណាម ឬស្តូបអនុស្សាវរីយ៍នៃនយោបាយឈ្នះៗ ក្នុង ន័យលើកទឹកចិត្តវៀតណាម និងរំលឹកនូវការដឹងគុណវៀតណាម កាលពី ៤០ ឆ្នាំមុន។ ការលើកទឹកចិត្តក្តី និងការដឹង គុណក្តី សុទ្ធតែធ្វើឲ្យវៀតណាម បន្តមើលស្រាល ឬបន្ទាបបន្ថោក ដល់ការដឹកនាំរដ្ឋាភិបាលរបស់លោក ហ៊ុន សែន កាន់តែហួសហេតុឡើង។

ជាក់ស្តែងរដ្ឋាភិបាលវៀតណាម បានបញ្ជាឲ្យទាហានរបស់ខ្លួន ចូលបោះជំរំ ឬបោះតង់ ១១៤ កន្លែងផ្សេងគ្នា នៅតាមបណ្តោយព្រំដែន ខេត្តកណ្តាល (៣១ កន្លែង) និងខេត្តតាកែវ (៨៣ កន្លែង) ដែលមិនទាន់ត្រូវបានរុះរើចេញវិញ ទាំងស្រុងផងទេ។

ទង្វើរបស់វៀតណាម គឺជាការគំរាមកំហែងយ៉ាងពិតប្រាកដ មកលើប្រទេសកម្ពុជា ទោះបីនៅក្រោមលេសថា « វិធានការរឹតបន្តឹងការចេញ-ចូលតាមច្រកព្រំដែន ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ (Covid-19)» ក្តី។ ទង្វើ ទាំងនោះ ជាការរំលោភធ្ងន់ធ្ងរទៅលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ ដែលវៀតណាម ជាម្ចាស់ហត្ថលេខីផងដែរ ជាពិសេសរំលោភឯកសារទី២ នៃកិច្ចព្រមព្រៀងនេះ ត្រង់មាត្រា១ ចំណុច ២-គ. ដែលចែងថា *«ជៀសវាងការជ្រៀតជ្រែករបស់រដ្ឋដទៃៗទៀត ដោយផ្ទាល់ ឬដោយប្រយោល ទោះតាមរូបភាពណាក៏ដោយ»* និងត្រង់**ចំណុច ២-ង.** ដែល ចែងថា *«ជៀសវាងការគំរាមកំហែង ឬប្រើកម្លាំងប្រឆាំងនឹងបូរណភាពដែនដី ឬឯករាជ្យនយោបាយនៃរដ្ឋណាមួយ ឬដោយឥរិយាបថណាមួយ ដែលមិនស្របនឹងគោលបំណងរបស់អង្គការសហប្រជាជាតិ (អ.ស.ប)»*។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា មានការព្រួយបារម្ភចំពោះហានិភ័យរបស់កម្ពុជា ទៅថ្ងៃអនាគតជាហូរហែរ បន្ទាប់ពី បានឃើញក្រសួងការពារជាតិ របស់លោក ទៀ បាញ់ លើកឡើងនូវគម្រោងកសាងស្តូបអនុស្សាវរីយ៍នៃយោបាយឈ្នះៗ បន្ថែម «ខេត្តកោះកុង ឧត្តរមានជ័យ ប៉ៃលិន និង កំពង់ស្ពឺ» ដែលបានផ្សព្វផ្សាយកាលពីថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០២០។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សូមអំពាវនាវយ៉ាងទទូចដល់រដ្ឋាភិបាលលោក ហ៊ុន សែន ឲ្យផ្អាកគម្រោងទាំងអស់ លើ ករណីសាងស្តូបវៀតណាម ឬស្តូបអនុស្សាវរីយ៍នៃនយោបាយបាយឈ្នះៗ ដោយងាកទៅពិនិត្យមើល «ដំណោះស្រាយ នយោបាយកម្ពុជា ស្វែងរកឯកភាពជាតិ» រួចត្រូវប្រើប្រាស់យន្តការអន្តរជាតិនានា ទប់ស្កាត់ទាហានវៀតណាម កំពុងតែ គំរាមកំហែងមកលើភាគីកម្ពុជា នៅតាមបណ្តោយព្រំដែនសព្វថ្ងៃនេះ។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**ប្រធាន**

**ម៉ែន ណាត**


Contact Address: Senterveien 54, Apartment 112, 4790 Lillesand, NORWAY /Contact nathamonin@gmail.com /
Hompage: https://cwcicambodia.net